**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ០៧ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារអន្តរក្រសួង
# ចុះសិក្សាស្ថានភាពតាមបណ្តាប៉ុស្តិ៍ច្រកទ្វារព្រំដែន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពី ការបង្កើតរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ស្តីពី ការកំណត់និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- បានឃើញសេចក្តីសម្រេចលេខ៤៦ សសរ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១២ ស្តីពី ការបង្កើតគណៈបញ្ជាការដឹកនាំត្រួតពិនិត្យ និងលុបបំបាត់ការដាក់ប៉ុស្តិ៍ត្រួតពិនិត្យអនាធិបតេយ្យតាមផ្លូវគោក-ផ្លូវទឹក
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ១._**

ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួង ចុះសិក្សាស្ថានភាពតាមបណ្តាប៉ុស្តិ៍ច្រកទ្វារព្រំដែន ដែលមានសមាសភាពដូចខាងក្រោម៖

១-ឯកឧត្តមនាយឧត្តមសេនីយ៍ អ៊ុក គឹមលេខ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ប្រធាន



www.pheakdeylaw.com

| | | |
|---|---|---|
| ២-ឯកឧត្តម ប៊ុន ហុន | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣-ឯកឧត្តម ឡុង ផល | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤-ឯកឧត្តម សារុន ប៉ាឌី | ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធាននាយកដ្ឋានផ្ទៃក្នុង | សមាជិក |
| ៥-លោក ខៀវ សំអាន | អគ្គនាយករងនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៦-លោក គឹម មាសសុខសីហា | អគ្គនាយករងនៃអគ្គនាយកដ្ឋានកាំកុងត្រូល ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៧-លោក មាស ពិសិដ្ឋ | អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន ក្រសួងកសិកម្ម | សមាជិក |
| ៨-ឯកឧត្តម គឹម វឿនសោភ័ណ | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ | សមាជិក |
| ៩-ឯកឧត្តមឧត្តមសេនីយ៍ឯក ណុប វី | អគ្គនាយករងនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | សមាជិក |
| ១០-ឧត្តមសេនីយ៍ឯក ឆាយ ប៊ុណ្ណា | ប្រធាននាយកដ្ឋានច្រកទ្វារទី១ នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | សមាជិក |
| ១១-ឧត្តមសេនីយ៍ឯក សារិន សារ៉ែណូ | ប្រធាននាយកដ្ឋានច្រកទ្វារទី២ នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | សមាជិក |
| ១២-ឧត្តមសេនីយ៍ទោ ហាញ់ ចំរើន | អនុប្រធាននាយកដ្ឋានកណ្តាលព្រំដែន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |

**ប្រការ២.-**

ក្រុមការងារនេះមានភារកិច្ចជាសេនាធិការជូន រាជរដ្ឋាភិបាល ក្នុងការសិក្សាស្ថានភាពជាក់ស្តែង តាមបណ្តាប៉ុស្តិ៍ច្រកទ្វារព្រំដែន ដើម្បីផ្តួចផ្តើមយោបល់ សំដៅកែទម្រង់ ជានាប្រសិទ្ធភាពការងារ។

**ប្រការ៣.-**

ក្រុមការងារនេះមានសិទ្ធិ និងភារកិច្ចដូចខាងក្រោម៖

-ចុះសិក្សាស្រាវជ្រាវស្ថានភាពជាក់ស្តែងនៅប៉ុស្តិ៍ច្រកទ្វារព្រំដែន ដែលចាំបាច់

-ផ្តល់ព័ត៌មានទៅខេត្តពាក់ព័ន្ធ ដែលជាប្រធានទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែន ដើម្បីត្រៀម ឯកសារ របាយការណ៍ អំពីស្ថានភាពទូទៅ ការប្រព្រឹត្តទៅរបស់ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារ ព្រំដែន មន្ត្រីប្រតិបត្តិការ បញ្ហាប្រឈម និងសំណូមពរ

-មានសិទ្ធិប្រើប្រាស់ត្រាក្រសួងមហាផ្ទៃ

-ប្រើប្រាស់មន្ត្រីក្រោមឱវាទរបស់ខ្លួនតាមការចាំបាច់

-ក្នុងករណីចាំបាច់ទាក់ទងដល់ជំនាញរបស់ក្រសួង ស្ថាប័ននីមួយៗ ក្រុមការងារត្រូវរាយការណ៍ សុំមតិយោបល់ពីថ្នាក់ដឹកនាំរបស់ខ្លួន៕



www.pheakdeylaw.com

-ធ្វើរបាយការណ៍អំពីសភាពការណ៍ និងលទ្ធផលនៃការសិក្សាជូន សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈបញ្ជាការដឹកនាំត្រួតពិនិត្យ និងលុបបំបាត់ការដាក់ប៉ុស្តិ៍ត្រួតពិនិត្យអនាធិបតេយ្យតាមផ្លូវគោក-ផ្លូវទឹក។

**ប្រការ៤.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១៤ កើត ខែ មាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល៖</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com